# ប្រយោជន៍នៃដំណឹងល្អសម្រាប់សហគមន៍របស់អ្នក



**នៅក្នុង**លោកីយ៍សព្វថ្ងៃនេះ យើងតែងតែឮគេបញ្ចេញយោបល់ថា: «ការអនុវត្តតាមគោលការណ៍របស់សាសនាគ្រីស្ទានគ្មានប្រយោជន៍សោះ ។ ក៏មិនអាចប្រើការនោះបានទេនៅក្នុងសង្គមដ៏ស្មុគស្មាញរបស់សម័យនេះ» ។ ប៉ុន្តែ ក្នុងការសន្ទនាដែលបានរាយការណ៍មករវាងមេដឹកនាំសាសនាហិណ្ឌូម្នាក់ឈ្មោះលោក មហាន់ដាស់ ហ្គានឌី ហើយជនជាតិអង់គ្លេសម្នាក់ជាអតីតឧបរាជរបស់ប្រទេសឥណ្ឌា លោកអ៊ើរិន គឺបានត្រូវបញ្ចេញគំនិតផ្សេងទៀតដែលខុសគ្នាណាស់ពីយោបល់ខាងលើនេះ ។ លោកអ៊ើរិនបានសួរលោកហ្គានឌី ថាតើលោកគិតថាវិធីយ៉ាងណានឹងអាចជួយដោះស្រាយបញ្ហារវាងប្រទេសអង់គ្លេសនិងប្រទេសឥណ្ឌាបាននោះ ។ លោក ហ្គានឌីបានចាប់យកព្រះគម្ពីរមួយក្បាល បើកទៅម៉ាថាយជំពូកទី៥ ហើយមានប្រសាសន៍ថា: «កាលដែលប្រទេសលោកនិងប្រទេសរបស់ខ្ញុំ នឹងអាចចូលរួមក្នុងការប្រតិបត្តិតាមសេចក្ដីបង្រៀននៃព្រះយេស៊ូ ដែលទ្រង់មានបន្ទូលនៅលើភ្នំនោះ យើងនឹងអាចដោះស្រាយឱ្យរួចមិនគ្រាន់តែបញ្ហារបស់ប្រទេសយើងប៉ុណ្ណោះទេ គឺបញ្ហារបស់លោកីយ៍ទាំងមូលនឹងត្រូវបានដោះស្រាយឱ្យរួចដែរ» ។

ធម្មទាននោះថ្លែងអំពីការស្វែងរកនូវភាពខាងវិញ្ញាណ ហើយខិតខំធ្វើឱ្យមានគុណសម្បត្តិដូចជាស្លូតបូត មេត្រីចិត្ត មេត្តាករុណា ហើយសេចក្ដីស្រឡាញ់ចំពោះសេចក្ដីសុចរិតដែរ ។ ធម្មទាននេះមិនគ្រាន់តែផ្ដន្ទាទោសនូវឃាតកម្មនិងសេចក្ដីកំផិតប៉ុណ្ណោះទេ គឺព្រមទាំងកំហឹងនឹងគ្នា ព្រមទាំងគំនិតដែលប្រកបទៅដោយកាមតណ្ហាដែរ ។ ហើយថ្លែងជំទាស់នឹងការលះលែងគ្នាដោយមិនគិតមុខគិតក្រោយដែលបំបែកគ្រួសារ និងធ្វើឱ្យកូនក្មេងរងគ្រោះផង ។ ធម្មទាននេះចែងប្រាប់ថា: <គួរតែស្រឡាញ់មនុស្សដែលមិនចូលចិត្តអ្នក ឱ្យអំណាចដល់មនុស្សទ័លក្រឈប់ថ្កោលទោសអ្នកដទៃដោយឥតមេត្តាករុណា ត្រូវប្រព្រឹត្តចំពោះគេដូចជាលោកអ្នកចង់ឱ្យគេប្រព្រឹត្តនឹងលោកអ្នកដែរ> ។ ដំបូន្មានទាំងនេះ បើមនុស្សអនុវត្តតាម នឹងត្រូវបង្កបង្កើតឱ្យមានប្រយោជន៍ល្អយ៉ាងសម្បើម ។ កាលណាមនុស្សជាច្រើនអនុវត្តតាមគោលការណ៍ទាំងនេះក្នុងសហគមន៍របស់លោកអ្នក សហគមន៍នេះនឹងបានល្អប្រសើរមែន!

ស្មរបន្ទាល់ព្រះយេហូវ៉ាជាអ្នកមានអានុភាពដ៏ល្អតាមរបៀបនេះ។
ព្រះគម្ពីរបង្រៀនគេឱ្យដាក់កិត្តិយសទៅលើអាពាហ៍ពិពាហ៍។
កូនចៅរបស់ពួកគេបានត្រូវអប់រំឱ្យប្រព្រឹត្តតាមគោលការណ៍ត្រឹមត្រូវ។ ពួកគេចាត់ទុកក្រុមគ្រួសារជាការសំខាន់។
ក្រុមគ្រួសារដែលមានសាមគ្គីភាពនាំឱ្យមានប្រយោជន៍ដល់សហគមន៍អ្នក ថែមទាំងដល់សាសន៍របស់អ្នកដែរ។
ប្រវត្តិសាស្ត្រមនុស្សពោរពេញទៅដោយឧទាហរណ៍របស់មហាអំណាច
ដែលធ្លាក់ឧបអោនក្នុងកាលដែលសម្ព័ន្ធគ្រួសារបានត្រូវចុះថយ ហើយអំពើអសីលធមិបានចម្រើនលូតលាស់ទៅវិញ។
កាលដែលស្មរបន្ទាល់ព្រះយេហូវ៉ាមានអានុភាពទៅលើមនុស្សម្នាក់ៗ
និងក្រុមគ្រួសាជាច្រើនដើម្បីឱ្យប្រព្រឹត្តតាមគោលការណ៍គ្រីស្ទានក្នុងជីវភាពរបស់គេ
នោះសហគមន៍របស់អ្នកនឹងមិនសូវមានក្មេងពាល អំពើអសីលធមិ
ព្រមទាំងបទឧក្រិដ្ឋយ៉ាងច្រើនដូចពីមុននោះទៀតទេ។

**មនុស្សគ្រប់សញ្ជាតិ គ្រប់សម្បុរទាំងអស់ធ្វើការជាមួយគ្នា**

បញ្ហាដ៏ធំមួយដែលបៀតបៀនដល់សហគមន៍និងសាសន៍ជាច្រើននោះ
គឺជាការប្រកាន់ពូជសាសន៍។ ជាការផ្ទុយទៅវិញ
សាវ័កពេត្រុសមានប្រសាសន៍ថាៈ «ខ្ញុំយល់ថា
ព្រះមិនរើសមុខអ្នកណាទេ គឺនៅក្នុងគ្រប់ទាំងសាសន៍
អស់អ្នកណាដែលកោតខ្លាចដល់ទ្រង់ ព្រមទាំងប្រព្រឹត្តសុចរិត នោះគាប់ដល់ព្រះហឫទ័យទ្រង់ដែរ»។
ហើយសាវ័កប៉ុលបានសរសេរថាៈ «គ្មានសាសន៍យូដា ឬសាសន៍ក្រេក គ្មានបាវបំរើ ឬអ្នកជា គ្មានប្រុស
នឹងស្រីទៀតទេពីព្រោះអ្នករាល់គ្នាទាំងអស់រួមមកតែមួយ នៅក្នុងព្រះគ្រីស្ទយេស៊ូវ»។(កិច្ចការ ១០ៈ៣៤, ៣៥;
កាឡាទី ៣ៈ២៨) ស្មរបន្ទាល់ព្រះយេហូវ៉ាព្រមទទួលរឿងនេះ។
មនុស្សគ្រប់ជាតិហើយគ្រប់សម្បុរទាំងអស់នៅហើយធ្វើការជាមួយគ្នា នៅមន្ទីរចាត់ការពិពភលោក
នៅការិយាលយ័សាខានានា ហើយក្នុងក្រុមជំនុំទាំងឡាយដែរ។

**កាន់តាមសាសនាគ្រីស្ទានជាការមានប្រយោជន៍ តើសាសនាណាទៀតដែលបានសម្រេចការនេះបាន?**

នៅទ្វីបអាហ្វ្រិក
កុលសម្ព័ន្ធខ្លះមិនអាចរួបរួមគ្នាដោយគ្មានការប៉ះទង្គិចគ្នាឡើយ។
យ៉ាងណាក៏ដោយ នៅក្នុងសន្និបាតរបស់ស្មរបន្ទាល់យេហូវ៉ានៅទីនោះ
មនុស្សពីកុលសម្ព័ន្ធជាច្រើនបរិភោគ សម្រាន្ត
ហើយថ្វាយបង្គំជាមួយគ្នាដោយសុខដុមយ៉ាងពេញលេញ
ព្រមទាំងមានមិត្តភាពយ៉ាងរាក់ទាក់ទៀតផង។ មន្ត្រីរដ្ឋាភិបាលឆ្ងល់ណាស់កាលដែលពួកគេឃើញរឿងដ៏ល្អនេះ។
សារពតិមាននៃទីក្រុងញូវយ៉ក *អែមស្ទើដាមនូស* ដែលចេញថ្ងៃទី២ ខែសីហា
ឆ្នាំ១៩៨៥បានរៀបរាប់អំពីឧទាហរណ៍មួយនៃលទ្ធផលដែលបានមកពីសាមគ្គីភាពរបស់សាសនាគ្រីស្ទានពិត។
អត្ថាធិប្បាយនេះបានត្រូវបណ្តាលមកពីការពិនិត្យមើលមហាសន្និបាតអន្តរជាតិដែលបានរៀបរាប់ពីមុនមកនេះ
ដែលជាង២សែន៩ម៉ឺនស្មរបន្ទាល់បានរួមប្រជុំគ្នានៅទីក្រុងញូវយ៉ក។



«នៅគ្រប់ទីកន្លែងមានមនុស្សខ្មៅ មនុស្សស ហើយមនុស្សអាស៊ី ពីគ្រប់ថ្នាក់នៃជីវិតហើយពីគ្រប់ទិសនៃផែនដី បានមកប្រូបរួមជាមួយគ្នាយ៉ាងរីករាយហើយដែលគ្មានលក្ខខណ្ឌ។ . . . ស្នូរបន្ទាល់ព្រះយេហូវ៉ាដែលកំពុងថ្វាយបង្គំ ដែលមកពី១២០ប្រទេសបានត្រូវរស់ជាមួយគ្នា ហើយបានថ្វាយបង្គំជាមួយគ្នាដោយចិត្តមេត្រី ហើយដោយធ្វើយ៉ាងនេះគេបានបង្ហាញពួកអាមេរិកាំងរបៀបដែលការនេះអាចសម្រេចបានដោយងាយស្រួល។ . . . សន្និបាតនេះជាគំរូដ៏ប្រសើរអំពីរបៀបដែលមនុស្សអាចរស់នៅជាមួយគ្នាបាន ហើយធ្វើការជាមួយគ្នាដែរ»។

មនុស្សជាច្រើននិយាយថា ធ្វើតាមគោលការណ៍នៃសាសនាគ្រីស្ទាន គឺមិនមានប្រយោជន៍ក្នុងលោកីយ៍ទាន់សម័យនេះទេ។ ប៉ុន្តែ តើមានសាសនាឯទៀតដែលបានសម្រេចឬក៏អាចសម្រេចឱ្យមានផលប្រយោជន៍យ៉ាងល្អបាន? គោលការណ៍គ្រីស្ទាននឹងនាំឱ្យមានប្រយោជន៍ដ៏ពិតប្រាកដក្នុងសហគមន៍របស់អ្នក បើអនុវត្តតាមឥឡូវនេះ ហើយគោលការណ៍ទាំងនេះនឹងធ្វើជាមូលដ្ឋានដើម្បីរួបរួមដោយសាមគ្គីភាពនូវ«គ្រប់ទាំងសាសន៍ គ្រប់ទាំងពូជមនុស្ស គ្រប់ទាំងគ្រួសារ»នៅលើផែនដីទាំងមូល នៅក្រោមការគ្រប់គ្រងនៃព្រះរាជាណាចក្ររបស់ព្រះលើមនុស្សលោក។—វិវរណៈ ៧:៩, ១០

Copyright © 2004 Watchtower Bible and Tract Society of Pennsylvania. All rights reserved.